**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..២៨៨.....សហវ.ហក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៥

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**កម្មវត្ថុ:** ករណីសំណើសុំបន្ថែមវិសាលភាពមួយចំនួនដើម្បីអនុវត្តការចំណាយប្រាក់បេសកកម្មនៅក្នុង និងទៅក្រៅប្រទេស នៅក្រសួងអប់រំ យុវជននិងកីឡា ។

**យោង:** លិខិតលេខ៣៨៦៩ អយក.ហវ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងអប់រំ យុវជន និងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រេចជាគោលការណ៍ដូចខាងក្រោម ÷

ក- អនុញ្ញាតផ្តល់ជាប្រាក់ឧបត្ថម្ភជូនបុគ្គលិកសហព័ន្ធកីឡា គ្រូបង្វឹក គ្រូជំនួយ អាជ្ញាកណ្តាល ចៅក្រម និងកីឡាករគ្រប់ប្រភេទ រួមទាំងសិស្ស និស្សិត យុវជន បុគ្គលិកក្រុមហ៊ុន គ្រូមិនមែនក្របខ័ណ្ឌរដ្ឋនិងប្រជាពលរដ្ឋ មិនស្ថិតក្នុងវិសាលភាពដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យលេខ ២១៦ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ តាមអត្រាដូចខាងក្រោម ÷

១- បេសកកម្មក្នុងប្រទេស ÷ ឧបត្ថម្ភចំនួន ១៣៦ ០០០រៀល/ម្នាក់/១ថ្ងៃ ក្នុងនោះ ÷

- ស្នាក់នៅ ចំនួន ៨០ ០០០រៀល
- ហូបចុក ចំនួន ៤០ ០០០រៀល
- ប្រាក់ហោប៉ៅ ចំនួន ១៦ ០០០រៀល ។

២- បេសកកម្មទៅក្រៅប្រទេស ÷ ឧបត្ថម្ភចំនួន ២៣០ ដុល្លារអាមេរិក/ម្នាក់/១ថ្ងៃ ក្នុងនោះ ÷

- ស្នាក់នៅ ចំនួន ១៥០ ដុល្លារ
- ហូបចុក ចំនួន ៦០ ដុល្លារ
- ប្រាក់ហោប៉ៅ ចំនួន ២០ ដុល្លារ ។

៣- ចំពោះមុខចំណាយណាមួយខាងលើដែលត្រូវបានទទួលរ៉ាប់រងដោយភាគីអញ្ជើញ នោះថវិការដ្ឋមិនផ្តល់ជូនទៀតទេ ។ ក្នុងករណីដែលរាល់មុខចំណាយទាំងអស់ត្រូវបានធានារ៉ាប់រងទាំងស្រុងដោយភាគីអញ្ជើញគឺមានតែប្រាក់ហោប៉ៅប៉ុណ្ណោះដែលត្រូវផ្តល់ជូនជាប្រាក់ឧបត្ថម្ភនិងមានកម្រិតមិនលើសពី ១០(ដប់) ថ្ងៃ ។

៤- ការឧបត្ថម្ភនេះអនុវត្តចំពោះតែបេសកកម្មណាដែលត្រូវបានបញ្ជូន និងមានការទទួលស្គាល់ជាផ្លូវការពីក្រសួងអប់រំ យុវជននិងកីឡា តែប៉ុណ្ណោះ ។

៥- ចំណាយត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងប្រកាសលេខ ១៥៨៩ សហវ.ហក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីរបៀប និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធនានាជាធរមាន ។

ខ- ការប្រើប្រាស់ឥណទានថវិកា÷

១- ការចំណាយឧបត្ថម្ភបុគ្គលិកសហព័ន្ធកីឡា គ្រូបង្វឹក គ្រូជំនួយ អាជ្ញាកណ្តាល ចៅក្រម និងកីឡាករគ្រប់ប្រភេទ ត្រូវប្រើប្រាស់ឥណទានថវិកាក្នុងអនុគណនី ៦២០៣៥ (ឧបត្ថម្ភសហគមន៍កីឡានិងវប្បធម៌)

២- ការចំណាយឧបត្ថម្ភបេសកកម្មនៅក្នុងប្រទេសជូនសិស្ស និស្សិត យុវជន បុគ្គលិកក្រុមហ៊ុន គ្រូមិនមែនក្របខ័ណ្ឌរដ្ឋនិងប្រជាពលរដ្ឋ ត្រូវប្រើប្រាស់ឥណទានថវិកាក្នុងអនុគណនី ៦២០២៥ (អាហារូបករណ៍សម្រាប់សិក្សាស្រាវជ្រាវក្នុងប្រទេស)

៣- ការចំណាយឧបត្ថម្ភបេសកកម្មទៅក្រៅប្រទេសជូនសិស្ស និស្សិត យុវជន បុគ្គលិកក្រុមហ៊ុន គ្រូមិនមែនក្របខ័ណ្ឌរដ្ឋនិងប្រជាពលរដ្ឋ ត្រូវប្រើប្រាស់ឥណទានថវិកាក្នុងអនុគណនី ៦២០២៦ (អាហារូបករណ៍សម្រាប់សិក្សាស្រាវជ្រាវក្រៅប្រទេស) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

លេខ ៥៣ អយក.ចល
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនឹងត្រូវបញ្ជូនទៅ
គ្រប់អង្គភាពក្រោមឱវាទក្រសួង និងរាជធានី ខេត្ត
" ដើម្បីអនុវត្ត "
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥
តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
អគ្គនាយក

ចៅខ បូរ៉ាន់

ចម្លងជូន÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ «ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ